# អំពី "ប្រតិកម្ម" ប្រឆាំងមហាយានក្រោយរាជ្យព្រះបាទជ័យវរ្ម័នទី៧

ស្វាយ ពិសិដ្ឋ / ទស្ស សុមនាថ
អាជ្ញាធរអប្សរា

បើយើងក្រឡេកមើលទៅប្រវត្តិសាស្ត្រកម្ពុជា តាំងពីកើតឡើងមកទល់បច្ចុប្បន្ននេះ យើងឃើញថាការសណ្ដោសនិងការគោរពសាសនាអ្នកដទៃ ជាលក្ខណៈមួយគួរឲ្យកត់សម្គាល់។

នៅទីនេះ យើងនឹងពុំលើកយកជំនឿប្រភេទជីវចលមកពោលទេ ត្បិតនរណាក៏ដឹងដែរថាមានជីវិតរស់រវើក ហើយឆ្លងកាត់គ្រប់សម័យកាលដោយគ្មានឧបសគ្គឡើយ។ យើងនឹងយកតែសាសនាធំៗដែលមានប្រភពមកពីឥណ្ឌា ហើយដែលគេតែងលើកតម្កើងជាសាសនាផ្លូវការមកនិយាយ។

តឹកតាងចាស់ជាងគេបង្អស់ដែលប្រទះឃើញ គឺចេញពីសតវត្សទី៦មក ហើយសុទ្ធសឹងជាទីបូជា ឬបដិមាដែលចេញពីសាសនានិកាយខុសៗគ្នា ៖ កូនប្រាសាទព្រាហ្មណ៍សាងក្នុងល្អាងភ្នំ [១] ឬលើភ្នំ [២], បដិមាផ្សេងៗរាប់ពុំអស់... នេះពុំនិយាយពីសំណង់ព្រាហ្មណ៍ដែលសាងឡើងដើម្បីគ្របដណ្ដប់លើទីបូជាផ្នែកជីវចល ដែលមានពីមុនមកផង [៣]។ បើយកតែបដិមាមកពិនិត្យ ប្រការដែលគួរឲ្យចាប់អារម្មណ៍បំផុត គឺតំបន់អង្គរបុរី (*ខេត្តតាកែវ*) ត្បិតនៅក្នុងកូនតំបន់តែមួយ, ក្នុងសម័យកាលតែមួយ (*សម័យមុនអង្គរ, ជាពិសេស ស.វ.ទី៦*) យើងឃើញមានព្រះពុទ្ធរូបផង, រូបទេពនានានៃព្រហ្មញ្ញសាសនាគ្រប់និកាយផង។ ជំនឿសាសនាគ្រប់បែបយ៉ាងនោះ មានទំនាក់ទំនងជិតស្និតទៅវិស័យនយោបាយទៀត។ គេប្រទះឃើញសិលាចារិកបី [៤] ដែលគាត់តែងឡើងនៅតំបន់ខុសៗគ្នា ប៉ុន្តែដែលនិយាយពីយុទ្ធនាការនយោបាយតែមួយ ធ្វើឡើងទូទាំងប្រទេស នៅដើមស.វ.ទី៩។ ព្រឹត្តិការណ៍នោះ គឺការប្រកាសឯករាជ្យខ្មែរឲ្យនៅក្រោមស្ដេចចក្រពត្តិតែមួយអង្គគត់ ផុតពីក្រញាំ "ជ្វា"។ យើងពុំដឹងថា តើគេមានធ្វើសឹកសង្គ្រាម ឬអ្វីទៀតឡើយ ប៉ុន្តែដឹងថាគេប្រារព្ធពិធីសាសនាធំៗ ដើម្បីសម្រេចគោលដៅនោះ នៅតាមតំបន់នានានៃប្រទេស។ ឯសាសនាដែលយកមកប្រើ គឺព្រាហ្មណ៍ផង ពុទ្ធសាសនាផង។

នាចុងស.វ. ទី៩ – ដើមស.វ. ទី១០ យើងដឹងថាព្រះបាទយសោវរ្ម័ន ដែលជាស្ដេចកាន់ព្រហ្មញ្ញសាសនាយ៉ាងខ្ជាប់ខ្ជួន បានសាង "អាស្រម" [៥] តាមទីកន្លែងផ្សេងៗជាច្រើន ហើយក្នុងនោះខ្លះជាអាស្រមសម្រាប់ពុទ្ធសាសនិកដែរ ហៅជាសំស្ក្រឹតថា "សៅគតាស្រម"។ ចំណុចនេះក៏ពុំខុសអ្វីពីពត៌មានដែលយើងដឹងពីជំនាន់ព្រះបាទសូរ្យវរ្ម័នទី១ដែរ។ ព្រះរាជាអង្គនេះ ដែលជាសាសនិកនិកាយព្រះឥសូរពេញធឹង មានចេញព្រះអាលក្សណ៍នៅតំបន់លពបុរី (*ប្រទេសសៀម*) ឲ្យគេថែទាំគោរពទីបូជាគ្រប់បែបយ៉ាង ព្រមទាំងឲ្យគេធ្វើទោសដល់ជនណាដែលបង្កការរំខានដល់អារាមនានា

---

[១] ដូចជានៅល្អាងភ្នំមួយចំនួនក្នុងខេត្តកំពត ៖ ភ្នំខ្យង, ភ្នំផ្ងោក ។ល។

[២] ដូចជាប្រាសាទនៅចង្កេះភ្នំដា (*ខេត្តតាកែវ*) និងចង្កេះភ្នំហាន់ជ័យ (*ខេត្តកំពង់ចាម*)។

[៣] ដូចជារូង "ស្រីគ្រប់លក្ខណ៍" នៅភ្នំចាសិទ្ធ (*ខេត្តកណ្ដាល*)។

[៤] *សិលាចារិកស្តុកកក់ធំ (K.235, ខេត្តបច្ចឹមបុរី, ប្រទេសសៀម), សិលាចារិកវត្តសម្រោង (K.956, ខេត្តព្រៃវែង), សិលាចារិកមួយទៀតទើបនឹងរកឃើញនៅខេត្តនគររាជ (ប្រទេសសៀម)*។

[៥] "អាស្រម" ជំនាន់នោះ សំដៅកន្លែងសិក្សាសាសនា និងវិជ្ជាផ្សេងៗ។

សម្រាប់អ្នកធ្វើតបស ("ស្ថានតបស្វិ"), ព្រះសង្ឃនិកាយមហាយាន និង ថេរវាទ ("ភិក្សុមហាយានស្ថវិរ") ។

បើក្រឡេកមើលទៅមន្ត្រីជុំវិញព្រះរាជាវិញ ក៏យើងសង្កេតឃើញថាមានកាន់សាសនាខុសគ្នា ដោយឥតមានប្រទូស្តរាយអ្វីទាំងអស់។ ដូចជានៅក្រោមរាជ្យព្រះបាទរាជេន្ទ្រវរ្ម័ន និងព្រះបាទជ័យវរ្ម័នទី៥ជាដើម យើងដឹងថាមន្ត្រីធំម្នាក់នោះកាន់ព្រះពុទ្ធសាសនាមហាយាន មានទាំងសាងសំណង់សាសនានោះផង ពោលគឺប្រាសាទបាតជុំ រីឯមន្ត្រីម្នាក់ទៀតកាន់សាសនាព្រាហ្មណ៍ ហើយសង់ប្រាសាទបន្ទាយស្រីដ៏ត្រចះត្រចង់ទៀត។ នៅរាជ្យព្រះបាទជ័យវរ្ម័នទី៧ យើងឃើញថា ថ្វីត្បិតតែព្រះរាជាកាន់មហាយាន ហើយស្ថាបនាសំណង់សាសនានេះពេញទឹកពេញដី ក៏មានមន្ត្រីដែលនៅតែបន្តកាន់ព្រាហ្មណ៍ជាធម្មតា ដូចជាមន្ត្រីម្នាក់ជាព្រាហ្មណ៍ដែលគ្រប់គ្រងប្រាសាទ "ទ" តាំងពីដូនតាមក[៦]។ មិនតែប៉ុណ្ណោះ មន្ត្រីម្នាក់ទៀតមកដាំដើមពោធិ៍មួយដើម នៅកៀនជើងប្រាសាទប្រចាំព្រះរាជវាំងតែម្តង ពោលគឺ "ភិមានអាកាស" មានទាំងតម្កល់សិលាចារិកមួយផ្ទាំងជិតនោះផង។ ដើមពោធិ៍ នោះ សិលាចារិកនិយាយថាជានិមិត្តរូប ត្រីមូរ្តិ នៃព្រហ្មញ្ញសាសនាទាំងស្រុង (ព្រះព្រហ្ម, ព្រះនារាយណ៍, ព្រះឥសូរ)។

ការដែលពោលត្រួសៗបំផុតខាងលើនេះ គ្រាន់តែចង់បង្ហាញថាសាសនារស់នៅជាមួយគ្នាក្នុងសង្គមខ្មែរតែមួយ ដោយពុំមានជុលរមាស់អ្វីទាំងអស់។ រីឯសាសនាដែលព្រះរាជាកាន់ជាធម្មតាវិញ គឺតែងតែជាសាសនាព្រាហ្មណ៍ ។

លើកលែងតែនៅពាក់កណ្តាលស.វ.ទី១២ ដែលឃើញមានព្រះរាជាកាន់សាសនាព្រះពុទ្ធជាដំបូងបង្អស់។ ប៉ុន្តែរាជ្យនោះក៏ពុំវែង ហើយពុំខ្លាំងក្លាអ្វីប៉ុន្មានឡើយ។ ប្រហែលជាអាណាចក្រអង្គរចុះខ្សោយព្រមទាំងមានវិបត្តិតាំងពីចុងរាជ្យមុននេះទៀត ត្បិតយើងឃើញថា មានព្រះរាជាដែលពុំមានថ្វីដៃអ្វីសោយរាជ្យបន្តបន្ទាប់គ្នាក្នុងរយៈពេលខ្លី ហើយចប់ត្រឹមចាមវាយលុកយករាជធានីអង្គរបាន នៅគ.ស.១១៧៧។ ស្ថានភាពនោះធ្ងន់ធ្ងរគ្មានអ្វីផ្ទឹមបាន ព្រោះខ្មែរធ្លាប់តែខ្លាំងពូកែ ហើយពេលនោះសត្រូវមកអុកឡុកកាន់កាប់ព្រះនគរ។ បួនឆ្នាំក្រោយមក ពេលដែលរើបម្រះពីចាមរួច ព្រះរាជាក៏ស្ថាបនាសំណង់ព្រះពុទ្ធសាសនាមហាយាននៅគ្រប់ទីកន្លែង។ ប្រការនេះធ្វើឲ្យមានការបកស្រាយច្រើនយ៉ាង ប៉ុន្តែកត្តាមួយក្នុងចំណោមកត្តានានាប្រហែលជាយុទ្ធនាការចិត្តសាស្ត្រ ដែលព្រះបាទជ័យវរ្ម័នទី៧ធ្វើឡើង ដើម្បីឲ្យរាស្ត្រមានជំនឿលើអ្វីមួយឡើងវិញ ក្រោយពីបាក់ទឹកចិត្តដោយឃើញចាមបំផ្លាញនគរដ៏ថ្កុំថ្កើងរបស់ខ្លួនបាន ។ ប៉ុន្តែគួរពិចារណាថា តើមហាយាននោះខុសពីព្រហ្មញ្ញសាសនាដាច់ស្រឡះពីគ្នា ប្រៀបដូចខ្មៅនិងស ឬយ៉ាងណា?

បើមើលតែលើសំបកក្រៅ ឃើញថាខុសគ្នាច្រើន ដោយសារភិនភាគនិងព្រះនាមនៃទេពមហាយានមិនដូចនៅព្រហ្មញ្ញសាសនាឡើយ។ ទេពថ្មីមានជាអាទិ៍គឺ ៖

– ព្រះពុទ្ធអង្គ ក្នុងសភាពជាព្រះសង្គ្រោះ។ ឧទាហរណ៍ ព្រះពុទ្ធអង្គដែលជា "គ្រូថ្នាំ" (សំស្ក្រឹត ៖ ភៃសជ្យគុរុ)។

– ព្រះលោកេស្វរ ដែលជាពោធិសត្វនៅចាំសង្គ្រោះសត្វលោកនានា។ ព្រះពោធិសត្វនោះអាចបែងភាគទៅជាសត្វ មានសេះជាដើម ។

–ប្រាជ្ញាបារមី (សំស្ក្រឹត ៖ ប្រាជ្ញាបារមិតា) ដែលមានរូបភាពជាទេពស្រី ប៉ុន្តែដែលស្ទង់សញ្ញាណ "ប្រាជ្ញ" ពោលគឺចំណេះ។ ជួនកាល សិលាចារិកលើកទេពប្រាជ្ញាបារមីឡើងជាព្រះមាតានៃព្រះពុទ្ធអង្គ ។

គប្បីយើងកុំយល់ថាការដូរសាសនាផ្លូវការនេះ មានន័យថាគេលែងរាប់រកសាសនាព្រាហ្មណ៍។ ឧទាហរណ៍បញ្ជាក់ថាផ្ទុយពីនេះទៅវិញទេ ដូចមានពោលពីលើមកខ្លះហើយ។ ម្យ៉ាងទៀត បើពិនិត្យចម្លាក់នៅតាមប្រាសាទមហាយានទាំងនោះ ក៏ឃើញថាសាសនាព្រាហ្មណ៍នៅរស់រវើកជាធម្មតា ។

ហេតុដូច្នោះហើយបានជាផុតអំពីរាជ្យនោះមក ព្រហ្មញ្ញសាសនាក៏ត្រឡប់មកជាសាសនាផ្លូវការ (គឺព្រះរាជាកាន់) ដូចមុនវិញ។ យោងហេតុផលខាងលើនេះ ការត្រឡប់មករកសាសនាមុនវិញពុំមានអ្វីដែលគួរប្រដូចទៅបដិវត្តន៍ធំធេងណាមួយឡើយ។ ប៉ុន្តែយ៉ាងណាក៏ដោយ អ្វីដែលជានិមិត្តរូបធំបង្អស់នៃព្រះពុទ្ធសាសនា គេយល់ថាគប្បីដកចេញ បើពុំដូច្នោះទេ តើចាំបាច់ដូរសាសនាធ្វើអ្វី ? រីឯនិមិត្តរូបដ៏សំខាន់បំផុតនៃព្រះពុទ្ធសាសនា មិនគឺអ្វីក្រៅពីព្រះពុទ្ធអង្គឡើយ ។ បើរូបទេពដទៃទៀត ដូចជារូបព្រះលោកេស្វរ, ប្រាជ្ញា... គេទុកឲ្យនៅដដែល ពុំមានប៉ះពាល់ទេ។

ចំពោះព្រះពុទ្ធរូប បើជាបដិមា គេយកចេញពីកន្លែងដើម។ ក្នុងករណីប្រាសាទបាយន្ត័ជាដើម គឺគេយកព្រះរូប "ជ័យពុទ្ធមហានាថ" ដែលធ្លាប់តម្កល់ជាព្រះជីនៅទីនោះ ទម្លាក់ចោលទៅក្នុងអណ្តូងប្រាសាទ។ បើជាចម្លាក់នៅតាមផ្ទាំងវិញ (ហោជាង, ជ័ត្តរ, សសរ...) គឺគេដាប់ចេញ។ បើអាចធ្វើបាន គេកែរូបព្រះពុទ្ធឲ្យទៅជាលិង្គ, ជាតាឥសី, ជាស្រីរាំ...។ យើងពុំដែលប្រទះឃើញស្នាមដាប់កន្លែងណាមួយ ដែលធ្វើឲ្យជឿ ឬសង្ស័យថា

៦.សិលាចារិកនៅប្រាសាទ"ទ" ពោលលើកតម្កើងយ៉ាងវែងអំពីព្រះបាទជ័យវរ្ម័នទី៧ ហើយលើកតម្កើងគ្រួសានៃមន្ត្រីនោះ ដែលកាន់ខ្ជាប់នូវព្រហ្មញ្ញសាសនាផង ។



រូបលេខ១១- ប្រាសាទព្រះខ័ន ៖
ព្រះពុទ្ធអង្គដែលគេដាប់ចេញពីហោជាង



រូបលេខ១២- ប្រាសាទក្រោលគោ ៖
ព្រះពុទ្ធអង្គដែល គេកែជាលិង្គ (ទីនេះកែពុំទាន់ចប់ នៅសល់ព្រះភ័ក្ត្រ)



រូបលេខ១៣- ប្រាសាទព្រះខ័ន ៖
ព្រះពុទ្ធអង្គដែលគេ កែជាស្រីរាំ

ជាលទ្ធផលនៃការបំផ្លិចបំផ្លាញ, ការស្អប់ខ្ពើមសម្បា ឬជា "ប្រតិកម្ម" អ្វីមួយសោះ។ ផ្ទុយទៅវិញ យើងសង្កេតឃើញថា បើគេដាប់រូបព្រះពុទ្ធចេញពីចង្កោមរូបអ្វីមួយ ក៏គេប្រិតប្រៀង មិនឲ្យការដាប់នោះរាលដាលខូចរូបដទៃដែលនៅជាមួយគ្នា ។

ករណីនៃព្រះពុទ្ធរូបដែលឆ្លាក់នៅលើស្លឹករកា គួរជាទីកត់សម្គាល់ក្រៃលែង។ កំពែងក្នុងក្រៅនៃប្រាសាទនានាជំនាន់ព្រះបាទជ័យវរ្ម័នទី៧ តែងមានស្លឹករកាបន្តបតម្រៀបជួរហែរគ្នាពីលើ។ សន្លឹកនិមួយៗឆ្លាក់ព្រះពុទ្ធរូបទាំងសងខាង។ បើរាប់ចំនួនចម្លាក់ព្រះពុទ្ធដែលមាននៅលើស្លឹករកាតាមប្រាសាទនិមួយៗ ដូចជាបន្ទាយក្ដី, ព្រះខ័ន, តាព្រហ្ម... ឃើញថាពុំអាចគណនាឡើយ។ ដូច្នេះការដែលគេដាប់យកព្រះពុទ្ធរូបម្ដងមួយៗចេញ ដោយប្រយ័ត្នពុំឲ្យខូចខាតដល់ស្លឹកនោះ ដើម្បីទុកឲ្យនៅកន្លែងលំអកំពែងដដែល ឃើញថាជាការងារច្រំដែលៗមួយ ដែលគួរឲ្យធុញថប់ខ្លាំងណាស់។ ប្រសិនបើការដាប់រូបរាប់សែននេះជាប្រតិកម្មប្រឆាំងនឹងពុទ្ធសាសនា ប្រហែលជាពុំចាំបាច់ខាតពេល, ខាតកម្លាំង និងពិបាកអំណត់ដល់ម្ល៉េះឡើយ គឺគ្រាន់តែទម្លាក់ស្លឹកតូចៗនោះចោលមកដី ឬមួយប្រមូលយកទៅចោលនៅកន្លែងណាមួយ ក៏ឃើញថាងាយស្រួលពន់ពេក។ នេះមកពីនៅតំបន់អង្គរគេនិយមថាដាប់យកព្រះពុទ្ធរូបចេញ ប៉ុន្តែទុកស្លឹករកាដដែល ដើម្បីបញ្ជាក់ច្បាស់ថាប្ដូរសាសនាមកដូចដើមវិញមែន។ ម្យ៉ាងទៀត ដូចបានពោលមកស្រាប់ គេពុំបានប៉ះពាល់ដល់ទេពមហាយានដទៃទៀតផង ដូចជាព្រះលោកេស្វរ និងទេព "ប្រាជ្ញា" ដែលមាននៅពាសវាលពាសកាល។ បើនៅក្រៅតំបន់អង្គរ ពុំសូវឃើញមាន ការដាប់នោះទៅទៀត ឧទាហរណ៍ នៅបន្ទាយឆ្មារ (ខេត្តបន្ទាយមានជ័យ), នៅប្រាសាទតាព្រហ្ម (ខេត្តតាកែវ) ...។

ប្រការទាំងប៉ុន្មានដែលលើកមកនេះ ពុំមានន័យថាការប្រកាន់យកសាសនាមហាយានដោយព្រះបាទជ័យវរ្ម័នទី៧ និងព្រះមហេសីទាំងពីរ





រូបលេខ១៤ និង១៥ ៖ ស្លឹករកានៅតាមកំពែងក្រៅនៃបន្ទាយក្ដី

អង្គនោះ ជាបាតុភូតតូចតាចទេ ។ សំណង់ដ៏ធំធេងនៅអង្គរ ឬក្រៅអង្គរទាំងប៉ុន្មាននោះជាតឹងតាងច្បាស់ហើយ ថាការប្ដូរសាសនានៅរាជ្យនោះ ជាការប្រែផ្លាស់មួយធំ ។ ប៉ុន្តែបើយើងយល់ថា ៖

១. ព្រះពុទ្ធសាសនាមហាយាននៃព្រះបាទជ័យវរ្ម័នទី៧ គ្មានជម្រៅទស្សនៈណាមួយ ដែលមានភាពផ្ទុយស្រឡះពីព្រហ្មញ្ញសាសនា ដែលធ្លាប់មានមកនោះឡើយ,

២. នៅក្នុងរាជ្យនោះ ព្រហ្មញ្ញសាសនាមានគេប្រតិបត្តិរៀងមកពុំដែលដាច់,

នោះយើងអាចសន្និដ្ឋានថា ពុំមានបដិវត្តន៍អ្វីដែលមានភាពក្រឡាប់ចាក់ឡើយ។ លុះយល់ដូច្នេះហើយ ទើបយើងអាចជឿថាការត្រឡប់មករកព្រហ្មញ្ញសាសនាជាផ្លូវការវិញ ក៏ពុំមែនជាបដិវត្តន៍ក្រឡាប់ចាក់ដូចគ្នាដែរ។

មកពីពុំមានការទាត់ចោល ឬប្រចាំងដាច់អហង្ការនេះឯងហើយ បានជាគេខំកែសំណង់មហាយានឲ្យមានបែបផែនទៅរកទីបូជាព្រហ្មញ្ញសាសនាខ្លះៗវិញ តាមសម្រួល។